ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សន្តាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៦៦
ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩
សាលដីកា
លេខ ៧៥ "VIII"
ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០

# សាលដីកា
# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.លោក [redacted] ប្រធាន

២.លោក [redacted] ចៅក្រម (របាយការណ៍)

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ២៨០ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីវ៉ាន់ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៤១ ស.ស "ក្រVII.ធ" ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមាន៖

-ជនត្រូវចោទឈ្មោះ [redacted] ឡៃហ្វូត ភេទប្រុស អាយុ៧៩ឆ្នាំ ជនជាតិខ្មែរ មុខរបរចាស់ជរា មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted]

Scanned with CamScanner

[redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន ០៣នាក់ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

-លោក [redacted] ម៉ាច ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ ។

<u>ត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖</u> **មួលបរិហារបង្កាច់កេរ្តិ៍** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣១១ និង ៣១២ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីវ៉ាន់ ភេទប្រុស អាយុ៦១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] រាជធានីភ្នំពេញ ។ (អ្នកប្តឹងសាទុក្ខ)

-លោក [redacted] ដល្លា ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

**អំពីអង្គហេតុ៖**

កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៤ ឈ្មោះ [redacted] ឡៃហួត បានធ្វើពាក្យបណ្តឹងប្តឹងឈ្មោះ [redacted] លីវ៉ាន់ ពីបទបរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅចំណុចហាងកាហ្វេ ភូមិស្វែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។ ក្រោយមកលោកព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ បានធ្វើការចោទប្រកាន់ឈ្មោះ [redacted] លីវ៉ាន់ ហើយចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ ក៏បានចេញសាលក្រមព្រហ្មទណ្ឌលេខ ១៦៨៧ គ.ភ.ព.ព្រ.ទ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ បង្គាប់ឱ្យឈ្មោះ [redacted] លីវ៉ាន់ សងសំណងទៅភាគីដើមបណ្តឹង ប៉ុន្តែសាលក្រមនេះត្រូវបានសាលាឧទ្ធរណ៍បដិសេធ តាមអំណាចសាលដីកាលេខ ៦៧ III (ណ) ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ដោយយល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ និងសាក្សីចំនួន ០៤នាក់ បានបញ្ជាក់ថាឈ្មោះ [redacted] លីវ៉ាន់ មិនបាននៅកន្លែងកើតហេតុ និងមានវិមតិសង្ស័យព្រោះដើមបណ្តឹងមិនបានស្តាប់ឮដោយផ្ទាល់ ដោយសំអាងតែលើការអះអាងរបស់សាក្សីម្នាក់តែប៉ុណ្ណោះ ។ លុះរហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ តុលាការកំពូលបានចេញសាលដីកាលេខ ១០៦ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ បានសម្រេច៖

១-បដិសេធបណ្តឹងសាទុក្ខលេខ ៣១៧ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ឡៃហួត ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦៧ III (ណ) ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៥៧១ ត.ព្រ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.លើកលែងចោទប្រកាន់ឈ្មោះ [redacted] ឡៃហួត ភេទប្រុស អាយុ៧៩ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពង់ចាម មុខរបរជាង ទីលំនៅសព្វថ្ងៃនៅភូមិ [redacted]



Scanned with CamScanner

[redacted] ខេត្តកំពង់ចាម ប្រពន្ធឈ្មោះ [redacted] ខ្សែសេង មានកូន០៣នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ពីបទ ប្តឹងបរិហារបង្កាច់កេរ្តិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា ២៤៧ នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ២១ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] លីវ៉ាន់ ដែលប្តឹងមិនសុខចិត្តនឹងដីកាដំណោះស្រាយលេខ ៥៧១ ត.ព្រ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកំពង់ចាម ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤១ សស.ក្រVII "ធ" ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] លីវ៉ាន់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់ដីកាដំណោះស្រាយលេខ ៥៧១ ត.ព្រ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការដដែល ។

៣-សាលដីកានេះប្រកាសជាអសាធារណៈ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ ២៨០ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីវ៉ាន់ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤១ សស.ក្រVII "ធ" ចុះថ្ងៃទី០៦ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

-យល់ឃើញថា ការដែលជនត្រូវចោទត្រូវបានសភាស៊ើបសួរ សម្រេចតម្កល់ដីកាសម្រេចឱ្យរួចផុតពីបទចោទរបស់ចៅក្រមស៊ើបសួរនោះ ជាការត្រឹមត្រូវហើយដោយហេតុថា ក្នុងសម្តាងរបស់សភាស៊ើបសួរ ជនត្រូវចោទប្តឹងដើមបណ្តឹងពីបទបរិហារតែប៉ុណ្ណោះ មិនមានចេតនាទុច្ចរិត ដើម្បីឱ្យដើមបណ្តឹងទទួលរងវិន័យ ឬទោសទណ្ឌនោះទេ ។

ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យ៖

-បណ្តឹងសាទុក្ខលេខ ២៨០ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] លីវ៉ាន់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសទៅនឹងគតិច្បាប់ ។

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤១ សស.ក្រVII "ធ" ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។



Scanned with CamScanner

+ឈ្មោះ [redacted] លីវ៉ាន់ ជាដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយថា៖ ខ្ញុំបាទប្តឹងសាទុក្ខមកនេះដោយហេតុថា ឈ្មោះ [redacted] ឡៃហួត មកប្តឹងខ្ញុំមុន ខ្ញុំក៏បានប្តឹងបកទៅវិញ គាត់បានប្តឹងមកលើរូបខ្ញុំចំនួន ០២ដង ហើយ គឺលើកទី១ នៅសាលាដំបូងរាជធានីភ្នំពេញ ប៉ុន្តែព្រះរាជអាជ្ញាបានលើកលែងចោទប្រកាន់ ចំណែកលើកទី២ គាត់ប្តឹងខ្ញុំថាខ្ញុំជេរគាត់នៅហាងកាហ្វេ មកដល់តុលាការកំពូលបានសម្រេចឱ្យខ្ញុំរួចខ្លួនពីបទចោទប្រកាន់ បន្ទាប់មកខ្ញុំបានសាលដីកានោះហើយក៏បានប្តឹងទៅគាត់វិញ ខ្ញុំ និងគាត់ជាបងប្អូននឹងគ្នា ដោយសារតែគាត់ពូកែប្តឹងមកលើខ្ញុំពេក ទើបខ្ញុំទ្រាំមិនបាន ។

សំណូមពរៈ សូមតុលាការជួយរកយុត្តិធម៌ឱ្យខ្ញុំបាទផង ។

+លោក [redacted] ផល្លា ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានថា៖ មូលហេតុដែលកូនក្តីខ្ញុំបាទមិនសុខចិត្ត នឹងសាលដីកាសភាស៊ើបសួរសាលាឧទ្ធរណ៍ ករណីកូនក្តីខ្ញុំប្តឹងពីបទ ប្តឹងបរិហាបង្កាច់កេរ្តិ៍ ដោយយោងទៅលើសាលដីកាកន្លងមកបុគ្គលឈ្មោះ [redacted] ឡៃហួត ជាជនត្រូវចោទធ្លាប់បានប្តឹងកូនក្តីខ្ញុំជាច្រើនដងក្នុងរឿងព្រហ្មទណ្ឌ ពីបទ បរិហាកេរ្តិ៍ជាសាធារណៈ ប៉ុន្តែលទ្ធផលចុងក្រោយ តាមរយៈសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ១០៦ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ របស់តុលាការកំពូល បានតម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចឱ្យកូនក្តីខ្លួនរួចខ្លួនពីការចោទប្រកាន់ ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ ។

សំណូមពរៈ សូមតុលាការសម្រេចបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍វិញ ។

+លោក [redacted] ម៉ាច ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទធ្វើសេចក្តីសន្និដ្ឋានថា៖ ដើមឡើយលោក [redacted] លីវ៉ាន់ ប្តឹងកូនក្តីខ្ញុំបាទពីរឿងជំពាក់លុយ មូលហេតុដែលប្តឹងគឺឈ្មោះ [redacted] លីវ៉ាន់ បានទៅនិយាយនៅហាងកាហ្វេមួយកន្លែងថា ឈ្មោះ [redacted] ឡៃហួត ជំពាក់លុយខ្លួនមិនព្រមសង ។ ដោយហេតុថា កូនក្តីខ្ញុំបានទទួលទោសរួចហើយ ចំណែកឯលុយក៏បានសងរួចរាល់ហើយដែរ ហេតុដូច្នេះហើយទើបតុលាការខេត្តកំពង់ចាម និងសាលាឧទ្ធរណ៍បានសម្រេចលើកលែងចោទប្រកាន់មកលើកូនក្តីខ្ញុំបាទ ។

សំណូមពរៈ សូមតុលាការសម្រេចតម្កល់ដីកាសម្រេចរបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៨០ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] លីវ៉ាន់ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

២-យល់ឃើញថា ការដែលដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជា មេធាវីការពារក្ដីបានអះអាងនាពេលដេញដោលនេះថា កន្លងមក បុគ្គលឈ្មោះ [redacted] ឡៃហួត ជាជនត្រូវចោទធ្លាប់បានប្ដឹងខ្លួនជាច្រើនដងក្នុងរឿងព្រហ្មទណ្ឌ ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ ប៉ុន្តែលទ្ធផលចុងក្រោយ តាមរយៈសាលដីកាព្រហ្មទណ្ឌស្ដពីរលេខ ១០៦ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ របស់តុលាការកំពូល បានតម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចឱ្យខ្លួនរួចខ្លួនពីបទចោទប្រកាន់ ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ ហេតុនេះតាមរយៈសាលដីកាជាន់ខ្ពស់នេះ ភាគីខ្លួនប្ដឹងតបទៅលើបុគ្គលឈ្មោះ [redacted] ឡៃហួត ពីបទ បរិហារកេរ្តិ៍ជាសាធារណៈនោះ ជាការមិនត្រឹមត្រូវទេ ព្រោះថា តាមមាត្រា ៣១១ (បទប្ដឹងបរិហាបង្កាច់កេរ្តិ៍) នៃក្រមព្រហ្មទណ្ឌ បានកំណត់ថា ការប្ដឹងបរិហារបង្កាច់កេរ្តិ៍ គឺជាអំពើប្ដឹងបរិហារអំពីអំពើដែលគេដឹងថាមិនពិតហើយដែលនាំឱ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ឬវិន័យ កាលបើការប្ដឹងបរិហារនេះ ត្រូវបានផ្ញើទៅដល់អាជ្ញាធរសមត្ថកិច្ច ។ ធាតុផ្សំនៃបទល្មើសក្នុងមាត្រានេះ សំដៅដល់ការប្ដឹងបរិហារធ្វើឡើងដោយចេតនាទុច្ចរិតប្រឆាំងបុគ្គលណាម្នាក់ ហើយការប្ដឹងនេះមានលក្ខណៈបង្កាច់កេរ្តិ៍ ។ ករណីនេះ អំពើដែលបុគ្គលឈ្មោះ [redacted] ឡៃហួត ធ្លាប់ប្ដឹងកន្លងមក គឺជាអង្គហេតុដោយភ្ជាប់ជាមួយនូវភស្តុតាងមួយចំនួន ដែលមានការពាក់ព័ន្ធនឹងភាគីដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ ដែលមិនមែនបណ្ដឹងសាមញ្ញទេ រហូតដល់សាលាដំបូងក៏ធ្លាប់បានប្រកាសទោសលើដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីវ៉ាន់ ក្នុងអង្គហេតុដែលជនត្រូវចោទឈ្មោះ [redacted] ឡៃហួត បានប្ដឹង ឯការសម្រេចឱ្យឈ្មោះ [redacted] លីវ៉ាន់ រួចផុតបទចោទដោយតុលាការជាន់ខ្ពស់ គឺជាការវាយតម្លៃភស្តុតាងដោយឆន្ទានុសិទ្ធិប៉ុណ្ណោះ ។ ជាវិបាក ការប្ដឹងរបស់បុគ្គលឈ្មោះ [redacted] ឡៃហួត កន្លងមក មិនអាចចាត់ទុកថាជាការប្ដឹងបរិហារអំពីអំពើដែលមិនពិតឡើយ ។ ដូច្នេះ នត្ថិភាពនៃបទល្មើសតាមមាត្រា ៣១១ នៃក្រមព្រហ្មទណ្ឌ ។

៣-យល់ឃើញថា តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា រឿងក្ដីនេះសភាស៊ើបសួរសម្រេចត្រឹមត្រូវហើយ ដោយហេតុថា កន្លងមកជនត្រូវចោទបានប្ដឹងដើមបណ្ដឹងរដ្ឋប្បវេណីពីបទ បរិហារកេរ្តិ៍ តែប៉ុណ្ណោះ ដែលមិនបានបង្ហាញអំពីចេតនាទុច្ចរិតរបស់ជនត្រូវចោទនោះទេ ហេតុនេះសុំតម្កល់សាលដីកាសភាស៊ើបសួរ ។ ករណីនេះ តុលាការកំពូលបានពិចារណាដូចមានក្នុងសំអាងហេតុខាងលើនេះ ។

៤-យល់ឃើញថា សាលដីកាលេខ ៤១ សស.ក្រVII "ធ" ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## សម្រេច

១-បដិសេធបណ្ដឹងសាទុក្ខលេខ ២៨០ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីវ៉ាន់ ។

២-តម្កល់សាលដីកាលេខ ៤១ សស.ក្រVII "ធ" ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ទុកជាបានការ ។

Scanned with CamScanner

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ
ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ។

Scanned with CamScanner